**យើងជឿថា មានព្រះតែមួយគត់** ។ ព្រះនេះបានបង្កើតអ្វីៗទាំងអស់ ទាំងរបស់មើលឃើញ ទាំងរបស់មើលមិនឃើញ ដោយសារព្រះបន្ទូលព្រះអង្គ ។ ព្រះដ៏គង់នៅអស់កល្បនេះ ទ្រង់ជាវិញ្ញាណ ។ ព្រះអង្គមានចរិត៣ គឺព្រះវរបិតា ព្រះរាជបុត្រា (យេស៊ូ) និងព្រះវិញ្ញាណបរិសុទ្ធ ។ ជាដំបូង ការនេះមើលទៅពិបាកឱ្យយល់ ប៉ុន្តែមានសេចក្តីយោងជាច្រើនអំពីភាពត្រីឯកនៅក្នុងគម្ពីរគ្រិស្តបរិស័ទ ។ នេះពិបាកឱ្យយល់ ព្រោះគ្មាននរណាយល់បានពេញលេញអំពីពិភពវិញ្ញាណបានឡើយ ។ តើសត្វឆ្កែ ពិតជាអាចយល់ពីចរិតរបស់មនុស្សបានឬ?

ព្រះយេស៊ូជាព្រះនៅលើផែនដី កាលព្រះអង្គបានយាងលើផែនដី ។ ទ្រង់ជាព្រះគង់ក្នុងចំណោមយើង ។ ទ្រង់មានបន្ទូលថា «អ្នកដែលឃើញខ្ញុំ អ្នកនោះបានឃើញព្រះវរបិតាហើយ» ។ ព្រះយេស៊ូបានចាប់កំណើតដោយសារព្រះវិញ្ញាណបរិសុទ្ធយ៉ាងអស្ចារ្យ នឹងស្រ្តីព្រហ្មចារីម្នាក់ឈ្មោះ ម៉ារា នៅភូមិបេថ្លេហិម ប្រទេសអ៊ីស្រាអែល ។ ការប្រសូតដ៏អស្ចារ្យរបស់ទ្រង់ត្រូវបានថ្លែងទុកមកដោយព្យាការី មីកា ប្រមាណ ៨០០ឆ្នាំ មុនការប្រសូតរបស់ព្រះយេស៊ូ ។ ព្រះពុទ្ធក៏បានថ្លែងអំពីព្រះយេស៊ូផងដែរ ក្នុងនាមជាតួអង្គបរិសុទ្ធដែលត្រូវមក ៥០០ឆ្នាំ មុនព្រះយេស៊ូប្រសូត ។

ព្រះយេស៊ូ បានសោយទីវង្គតជាយញ្ញបូជាយ៉ាងឈឺចាប់នៅលើផែនដី ដើម្បីឱ្យអស់អ្នកដែលជឿដល់ទ្រង់ ហើយប្រែចិត្តចេញពីអំពើបាបរបស់ខ្លួន នឹងបានទទួលជីវិតអស់កល្បជានិច្ចជាមួយព្រះអង្គនៅស្ថានសួគ៌ ។ មានតែព្រះយេស៊ូមួយប៉ុណ្ណោះ ជាអ្នកសង្គ្រោះសង្គ្រោះរបស់យើងជាមួយព្រះដ៏ជាព្រះវរបិតា ។ ព្រះយេស៊ូបានសុគតនៅលើឈើឆ្កាង ខាងក្រៅក្រុងយេរូសាឡិម ហើយទ្រង់ត្រូវបានគេបញ្ចុះនៅក្នុងផ្នូរ ។ ក្នុងកាលដែលទ្រង់សុគតនោះ ព្រះយេស៊ូបានយាងចុះទៅស្ថាននរក ហើយដោះលែងព្រលឹងជាច្រើនដែលជាប់នៅទីនោះ ។

ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយជាច្រើនថ្ងៃក្រោយមក ព្រះយេស៊ូបានយាងទៅស្ថានសួគ៌ នៅចំពោះមុខស្មរបន្ទាល់ជាច្រើន ។

ព្រះយេស៊ូគឺជាចៅក្រមនៅទីចុងបំផុត ដល់អស់ទាំងមនុស្សរស់ និងមនុស្សស្លាប់ គ្រប់ជំនាន់ទាំងអស់ ។

១ ខ្ញុំជឿដល់ព្រះវរបិតា ជាព្រះដ៏មានគ្រប់ព្រះចេស្តា ជាព្រះបង្កើតផ្ទៃមេឃ និងផែនដី
២ ខ្ញុំជឿដល់ព្រះយេស៊ូ ជាព្រះរាជបុត្រាតែមួយគត់របស់ទ្រង់ ជាព្រះអម្ចាស់របស់យើង
៣ ព្រះអង្គបានចាប់កំណើតដោយសារព្រះវិញ្ញាណបរិសុទ្ធ ប្រសូតពីស្រ្តីព្រហ្មចារី ម៉ារា
៤ ព្រះអង្គរងទុក្ខវេទនា ក្រោមអំណាចប៉ុនទាស_ពីឡាត់ ត្រូវគេឆ្កាង បានសោយទីវង្គត និងត្រូវគេបញ្ចុះក្នុងផ្នូរ
៥ នៅថ្ងៃទីបី ទ្រង់មានព្រះជន្មរស់ឡើងវិញ
៦ ព្រះអង្គយាងទៅស្ថានសួគ៌ ហើយគង់នៅខាងស្តាំព្រះវរបិតាដ៏មានគ្រប់ព្រះចេស្តា
៧ ព្រះអង្គនឹងយាងត្រឡប់មកវិញ ដើម្បីនឹងជំនុំជំរះមនុស្សលោក ទាំងមនុស្សរស់ ទាំងមនុស្សស្លាប់

៨ ខ្ញុំជឿដល់ព្រះវិញ្ញាណបរិសុទ្ធ

៩ ខ្ញុំជឿដល់ក្រុមជំនុំបរិសុទ្ធនៅលើសាកលលោកៈ ជាសេចក្តីប្រកបរបស់ពួកបរិសុទ្ធ

១០ ការអត់ទោសពីអំពើបាប

១១ ការរស់ឡើងវិញនៃរូបកាយ

១២ និងជីវិតអស់កល្បជានិច្ច ។ អាម៉ែន ។

--------------------------------------------------------------------------------

សេចក្តីខាងក្រោមនេះវាយចម្លងចេញពីច្បាប់ចាស់ក្នុងសៀវភៅទំនុកដំកើង

លទ្ធិនេះ បានសម្តែងច្បាស់ក្នុងបទជំនឿនៃក្រុមសាវកៈ

- ខ្ញុំជឿព្រះវរបិតា ព្រះអង្គមានសព្វានុភាព ព្រះអង្គជាព្រះអទិករបង្កើតស្ថានសួគ៌ និងផែនដី ។

- ខ្ញុំជឿព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រាតែមួយរបស់ព្រះ ព្រះអង្គជាព្រះអម្ចាស់ជីវិត ព្រះអង្គបានចាប់បដិសន្ធិ និងក្រមុំព្រហ្មចារិនី ដោយព្រះវិញ្ញាណបរិសុទ្ធស្តេចមកសណ្ឋិតលើនាង ព្រះអង្គរងទុក្ខវេទនាជាប់នាឈើឆ្កាង ក្រោមអំណាចប៉ុនទាល_ពីឡាត់ កាលបានសោយទីវង្គតហើយ ព្រះបរមសពបានទទួលទីបញ្ចុះ ទាំងស្តេចចុះទៅកាន់ស្ថានឃុំព្រលឹងមនុស្សស្លាប់ផង លុះថ្ងៃទីបីព្រះអង្គមានព្រះជន្មរស់ឡើងវិញ ព្រះអង្គហោះទៅសោយសម្បត្តិសួគ៌ ស្ថិតខាងស្តាំព្រះវបិតា ។ ព្រះអង្គនឹងទ្រង់ស្តេចមកពីស្ថានសួគ៌វិញ ដើម្បីជំនុំជម្រះមនុស្សលោក ទោះទាំងមនុស្សរស់មនុស្សស្លាប់ ក៏ព្រះអង្គជំនុំជំរះទាំងអស់ ។

- ខ្ញុំជឿព្រះវិញ្ញាណបរិសុទ្ធ ហើយទុកចិត្តនឹងក្រុមគ្រីស្ទបរិស័ទសកលលោក ខ្ញុំជឿថា ក្រុមជុំនុំបរិសុទ្ធមានការទាក់ទងគ្នាហើយថា ព្រះអង្គប្រោសអភ័យទោសបាបអោយផង ។ ខ្ញុំជឿថា រូបកាយដ៏ចេះស្លាប់នេះ និងរស់ឡើងវិញ ប្រកបដោយជីវិតអង្វែងកល្ប ។ សាធុ ។

---